# អំពើពុករលួយក្រោមផ្លាក សិទ្ធិមនុស្ស

ខាងក្រោមនេះគឺជាការដកស្រង់ពី សេចក្តីប្រកាសព័ត៌មាន ចុះថ្ងៃទី២៨ ខែមេសា ឆ្នាំ២០០៧ នៃ គណៈកម្មការស្វែងរកការពិត របស់អតីតបុគ្គលិកផ្ទៃក្នុង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

គណៈកម្មការស្វែងរកការពិត របស់អតីតបុគ្គលិកផ្ទៃក្នុង មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា បាននឹងកំពុងធ្វើការងារប្រឆាំងនឹងអំពើពុករលួយ (ដូចជា ការរំលោភលើសេចក្តីទុកចិត្ត, ការកិបកេងថវិកាជំនួយ, បក្ខពួកគ្រួសារនិយម, ការរំលោភសិទ្ធិបុគ្គលិក) ដែលលោក កឹម សុខា បានប្រព្រឹត្តក្នុងមុខងារជាប្រធាន មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ។

ក្នុងរបាយការណ៍ដាក់ជូនអង្គការ IRI គណៈកម្មការស្វែងរកការពិតបានបញ្ជាក់អំពីភាពមិនស្មោះត្រង់របស់លោក កឹម សុខា ដែលឆ្លៀតកេងចំណេញយកតួនាទីជាប្រធានអង្គក្រៅរដ្ឋាភិបាលមួយ រួមទាំងពេលវេលាការងារ, សំភារៈ និងថវិកាជំនួយសំរាប់អង្គការមកប្រើប្រាស់ជាប្រយោជន៍បុគ្គលរបស់ខ្លួនដើម្បីរៀបចំបណ្តាញនយោបាយលាក់លៀមមួយក្រោមផ្លាកការងារសិទ្ធិមនុស្សក្នុងមហិច្ឆិតាត្រៀមធ្វើនយោបាយ និងបង្កើតគណបក្ស ។ ក្រោយពីអង្គការ IRI សំរេចផ្តាច់ជំនួយដោយសារមូលហេតុនៃភាពមិនស្មោះត្រង់នេះ ទើបលោក កឹម សុខា ប្រកាសលាលែងយ៉ាងគក់ក្រហល់ពីប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្ស ហើយងាកមកប្រកាសបង្កើតគណបក្សនយោបាយភ្លាម១តែម្តង ។

គណៈកម្មការស្វែងរកការពិត សូមបញ្ជាក់ថា : អ្វីដែលលោក កឹម សុខា វិលត្រឡប់ចូលធ្វើនយោបាយ និងបង្កើតគណបក្ស គឺជាការប្រើសិទ្ធិនយោបាយរបស់បុគ្គល ប៉ុន្តែការប្រើសិទ្ធិនេះពុំអាចជាវិធីគេចវេះពីការទទួលខុសត្រូវចំពោះមុខច្បាប់ពាក់ព័ន្ធនឹងបទពុករលួយ ( *រួមមាន ការរំលោភលើសេចក្តីទុកចិត្ត, ការកិបកេងថវិកាជំនួយ, បក្ខពួកគ្រួសារនិយម, ការរំលោភសិទ្ធិបុគ្គលិក* និងបទបរិហាកេរ្តិ៍ដែលលោក កឹម សុខា បានប្រព្រឹត្តក្នុងមុខងារអតីតភាពជាប្រធានមជ្ឈមណ្ឌលសិទ្ធិមនុស្សបាននោះទេ។ គណៈកម្មការស្វែងរកការពិត កំពុងបន្តការងារប្រវត្តិសាស្ត្រនេះជាដំណាក់កាល១រហូតដល់ចប់ចុងចប់ដើម ។

**ជ. គណៈកម្មការស្វែងរកការពិត**

| | | | |
|---|---|---|---|
| **ញ៉ែម វណ្ណថន** | **ហុង ហួង** | **សួទិន សាន់** | **បណ្ឌិត ឈឹម ផលធរុណ** |
| (ប្រធាន) | (អ្នកនាំពាក្យ) | | |

## ពីមុន ធ្លាប់បានលួចប្រាក់ខែបុគ្គលិកខ្លួនឯង
## ឥឡូវ រកឱកាសលួចលុយជាតិតែម្តង
## បើកគណបក្សផ្ទុះ រកស៊ីពុករលួយក្រោមផ្លាកសិទ្ធិមនុស្ស

# សូមប្រុងប្រយ័ត្នគោជំទាវខ្ចង

បុគ្គលម្នាក់ដែលមិនអាចដឹកនាំអង្គការក្រៅរដ្ឋាភិបាលតូចមួយឱ្យបានត្រឹមត្រូវផង ដោយសារពូកែតែលួចប្រាក់ខែបុគ្គលិកខ្លួនឯង ហើយប្រព្រឹត្តអំពើពុករលួយក្រោមផ្លាកសិទ្ធិមនុស្ស បុគ្គលនោះមិនអាចដឹកនាំប្រទេសជាតិបានទេ ។ មនុស្សខិលខូចបែបនេះ បើមានឱកាសដឹកនាំប្រទេសជាតិមែននោះ មិនដឹងជាពុករលួយដល់ណាទេ ហើយមិនដឹងជាប្រើអំណាចរបស់ខ្លួនដើម្បីលួចជាតិ និងលួចរាស្ត្រដល់ណាទេ!

កាលពីឆ្នាំទៅ គេបានបើកគណបក្សថ្មីមួយដើម្បីបោកបញ្ឆោតរាស្ត្រដោយអះអាងថាខ្លួនគេជាអ្នកប្រជាធិបតេយ្យមានបំណងការពារសិទ្ធិមនុស្ស ។

តាមការពិត គេបានក្លាយខ្លួនទៅជាអ្នកបំរើគណបក្សកាន់អំណាចសព្វថ្ងៃ ហើយគណបក្សកាន់អំណាចប្រើគេឱ្យវាយប្រហារគណបក្ស សម រង្ស៊ី ដែលជាគណបក្សប្រឆាំងដ៏ធំតែមួយគត់ ដែលបានចាក់ឫសចាក់គល់ទូទាំងប្រទេសជាង១២ឆ្នាំមកហើយ ។

គណបក្សកាន់អំណាចសព្វថ្ងៃភ័យខ្លាចតែគណបក្ស សម រង្ស៊ី មួយគត់ ពីព្រោះមានតែគណបក្ស សម រង្ស៊ី មួយគត់ ដែលអាចដណ្តើមយកជ័យជំនះលើគេក្នុងការបោះឆ្នោតខាងមុខនេះ ។ ដោយសារតែគណបក្សកាន់អំណាចភ័យខ្លាចគណបក្ស សម រង្ស៊ី នេះហើយ បានជាគេជួលគណបក្សតូចៗ និងគណបក្សថ្មីថ្មោងមួយចំនួន ឱ្យមកប៉ុនប៉ងបំបែកសម្លេងអ្នកស្នេហាជាតិនិងអ្នកប្រជាធិបតេយ្យពិតប្រាកដ ។

អ្នកនយោបាយខិលខូចដែលធ្លាប់លួចប្រាក់ខែបុគ្គលិកខ្លួនឯង ហើយដែលបុគ្គលិកទាំងនោះចំនួន១៦នាក់បានដាក់ពាក្យបណ្តឹងទៅតុលាការពីបទពុករលួយនិងបទរំលោភសេចក្តីទុកចិត្តរួចមកហើយនោះ អ្នកនយោបាយខិលខូចនោះបានក្លាយខ្លួនទៅជាចំណាប់ខ្មាំង គឺជាអ្នកបំរើដាច់ថ្លៃរបស់គណបក្សកាន់អំណាចសព្វថ្ងៃ ។ បើមិនធ្វើតាមបញ្ជាគណបក្សកាន់អំណាចទេ គណបក្សកាន់អំណាចនោះគេនឹងជំរុញឱ្យតុលាការក្រោមឱវាទគេ ចាត់ការឱ្យចាប់អ្នកនយោបាយខិលខូចនោះដាក់គុកជាពុំខាន ពីព្រោះសាមីខ្លួនមានកំហុសគួរឱ្យអៀនខ្មាសមែន ។

អ្នកនយោបាយដែលមានកំហុសធ្ងន់ធ្ងរដូចជាបានលួចលុយគេ ត្រូវបានគេប្រៀបធៀបដូចគោជំទាវខ្នង ។ ក្រោយពេលគេចាប់កំហុសរបស់ខ្លួនបានហើយ គេចាំតែចុចលើចំណុចខ្សោយរបស់ខ្លួន ។ ដូចគោជំទាវខ្នងអញ្ចឹង គឺពេលណាគេចុចលើដំទាវវា ពេលនោះវានឹងបោលភ្លាមដោយឥតមើលមុខមើលក្រោយឡើយ ។

រឿងគោជំទាវខ្នងនេះធ្វើឱ្យយើងនឹកឃើញដល់ករណីទ្រង់ នរោត្តម រណឫទ្ធិ ជាមេបក្សនយោបាយម្នាក់ ដែលត្រូវបានតុលាការកាត់ទោសឱ្យជាប់គុក១៨ខែពីបទពុករលួយ និងបទរំលោភសេចក្តីទុកចិត្ត គឺដូចបេះបិតរឿងមេបក្សនយោបាយដែលរកស៊ីខិលខូចក្រោមផ្លាកសិទ្ធិមនុស្ស ។ ដើម្បីរួចផុតពីការជាប់គុកទ្រង់ នរោត្តម រណឫទ្ធិ បានរត់គេចខ្លួនទៅបរទេស ពីព្រោះមិនព្រមបំរើគណបក្សកាន់អំណាចសព្វថ្ងៃដូចពេលមុនទៀត ។ តែមេបក្សនយោបាយមួយរូបទៀតនោះ នៅតែបន្តបំរើគេដដែលនៅក្នុងស្រុក ពីព្រោះខ្លាចគេចាប់ដាក់គុកដោយសារអំពើពុករលួយរបស់ខ្លួន ។

***